**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# សីលធម៌ និងលក្ខន្តិកៈចាំបាច់ផ្នែកសេដ្ឋកិច្ច ដើម្បីធានាឲ្យការធ្វើចំណាកស្រុកមានលក្ខណៈយុត្តិធម៌ វ័យឆ្លាត និងមនុស្សធម៌ជាងមុន


ស្រាវជ្រាវដោយ៖ លោក លឹម សុវណ្ណារ៉ា

ដោយមានការចូលរួមពី៖ លោកស្រី វ៉ាន់ ណារី

កញ្ញា យុត វណ្ណារ័ត្ន



ខែកញ្ញា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**


**កំណត់សម្គាល់**

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

# មាតិកា

I. សេចក្តីផ្តើម ........ 1

II. បញ្ហា និងការប្រឈមនឹងការធ្វើចំណាកស្រុករបស់ពលករកម្ពុជា........ 1

III. គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ........ 3

IV. ការអនុវត្តបានល្អនៅក្នុងប្រទេសកម្ពុជា ........ 4

V. សេក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ ........ 6

ឯកសារយោង ........ 9

## I. សេចក្តីផ្តើម

**១. និយមន័យនៃពាក្យពលករចំណាកស្រុក៖** អត្ថន័យនៃពាក្យ«**ពលករចំណាកស្រុក**» មិនត្រូវបានកំណត់ជាក់លាក់ជាលក្ខណៈសាកលនៅឡើយទេ រហូតមកដល់ពេលនេះ។ អត្ថន័យ នៃពាក្យពលករចំណាកស្រុកនេះ ត្រូវបានយល់ជាទូទៅថា គឺជាជនគ្រប់រូបដែលបានសម្រេចចិត្តក្នុងការធ្វើចំណាកស្រុកដោយសេរីដោយផ្អែកលើហេតុផលបុគ្គល ផ្ទាល់ខ្លួន និងដោយគ្មានការអន្តរាគមន៍បង្ខិតបង្ខំពីកត្តាខាងក្រៅ។ ដូច្នេះ ពលករចំណាកស្រុកគឺ សំដៅលើបុគ្គល និងសមាជិកក្រុមគ្រួសារដែលផ្លាស់ទីទៅកាន់បណ្តាប្រទេស ឬតំបន់ផ្សេងទៀត ក្នុងគោលបំណងធ្វើឲ្យមានភាពប្រសើរឡើងនូវធនធាន ឬលក្ខខ័ណ្ឌសង្គមសម្រាប់ខ្លួនផ្ទាល់ ព្រមទាំងបង្កើននូវក្តីសង្ឃឹមសម្រាប់ខ្លួនគេ ឬក្រុមគ្រួសាររបស់ពួកគេ។ ពលករចំណាកស្រុក ត្រូវបានបែងចែកទៅតាមប្រភេទដូចខាងក្រោម៖

- ពលករចំណាកស្រុកដោយបញ្ហាសេដ្ឋកិច្ច
- ពលករចំណាកស្រុកដោយស្របច្បាប់
- ពលករចំណាកស្រុកមិនស្របច្បាប់
- ពលករចំណាកស្រុកមានជំនាញ
- ពលករចំណាកស្រុកបណ្តោះអាសន្ន។[1]

**២. កិច្ចការពារ និងការផ្តល់សិទ្ធិអំណាច៖** កិច្ចការពារ និងការផ្តល់សិទ្ធិអំណាចដល់ពលករចំណាកស្រុកនៅតែជាបញ្ហាប្រឈមនៃគោលនយោបាយសំខាន់ៗសម្រាប់ពលករចំណាកស្រុក។ ពលករចំណាកស្រុកកម្ពុជា គឺភាគច្រើនជាពលករដែលមានជំនាញទាបមានចំណេះដឹងតិចតួច ឬគ្មានចំណេះដឹង។ ហេតុនេះហើយ បានជាពួកគេអាចនឹងត្រូវប្រឈមជាមួយបញ្ហាធ្ងន់ធ្ងរ និងករណីការកេងប្រវ័ញ្ច ឬការរំលោភបំពាននៅពេលដែលធ្វើការនៅក្រៅប្រទេស។ លើសពីនេះទៅទៀត ប្រភេទការងារដែលពួកគេបានធ្វើគឺស្ថិតក្នុងស្ថានភាពជាពលករចំណាកស្រុកដែលមានកម្រិតទាប គឺអាចធ្វើឲ្យពួកគេងាយនឹងជួបប្រទះការរើសអើងផ្នែកយេនឌ័រ ផ្នែករដ្ឋបាល ផ្នែកច្បាប់ និងហិរញ្ញវត្ថុ ក៏ដូចជាការប្រកាន់ពូជសាសន៍ផងដែរ។[2]

## II. បញ្ហា និងការប្រឈមនឹងការធ្វើចំណាកស្រុករបស់ពលករកម្ពុជា

**១.**រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាការធ្វើចំណាកស្រុកដើម្បីការងារ គឺជាការចូលរួមចំណែកដ៏ចម្បងផងដែរក្នុងការជំរុញភាពមានការងារធ្វើ និងការកាត់បន្ថយភាពក្រីក្រតាមរយៈថវិកា

[1] http://www.iom.int/key-migration-terms (accessed 01/08/2015)
[2] International Organization for Migration, "Safe Migration: A Pre-Departure Orientation Manual for Migrant Workers." Cambodia, 2010, p. 2.

ដែលបានផ្ញើពីបរទេស ដែលអាចផ្តល់ជាផលវិជ្ជមានទាំងនៅក្នុងគ្រួសារ និងជាតិ។[3] ប៉ុន្តែ ចំពោះការប្រឈម និងបញ្ហានានានៅតែបន្តមាន ដូចជា៖

**២.ការចំណាយខ្ពស់៖** តម្លៃសរុបនៃការបញ្ជូនពលករចំណាកស្រុកដោយស្របច្បាប់ទៅកាន់ប្រទេសថៃមានតម្លៃប្រហែល ៧០០ ដុល្លារ ខណៈពេលដែលតម្លៃសរុបនៃការបញ្ជូនពលករចំណាកស្រុកដោយស្របច្បាប់ទៅកាន់ប្រទេសម៉ាឡេស៊ីគឺមានតម្លៃពី ៨៤០ដុល្លារ ទៅ ១,២០០ដុល្លារ។ ប្រៀបធៀបជាមួយពលករចំណាកស្រុកមិនស្របច្បាប់ គឺចំណាយត្រឹមតែ ១០០ដុល្លារ សម្រាប់ការលួចទៅធ្វើការក្នុងប្រទេសថៃ ហើយនឹងមិនត្រូវរង់ចាំយូរចំពោះដំណើរការដើម្បីចេញដំណើរទៅធ្វើការនៅក្រៅប្រទេសឡើយ។[4]

**៣. ភាពខ្វះខាតនៃកិច្ចសន្យាដែលមានលក្ខណៈស្តង់ដា៖** កិច្ចសន្យាការងារ គឺជាឯកសារគោលដែលត្រូវមាន បានទទួលការពិនិត្យ និងចុះហត្ថលេខា នៅមុនពេលពលករធ្វើចំណាកស្រុកចេញទៅកាន់ប្រទេសគោលដៅ។ ខណៈពេលដែលធ្វើការនៅក្រៅប្រទេស ពលករចំណាកស្រុកនឹងត្រូវចងភ្ជាប់ដោយលក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាការងារ ហើយកិច្ចសន្យានេះគួរតែមានភាពច្បាស់លាស់ និងត្រូវបានប្រតិបត្តិដោយប្រទេសទាំងពីរ គឺប្រទេសដែលបញ្ជូន និងប្រទេសដែលទទួលពលករចំណាកស្រុក។ ទោះបីជាយ៉ាងណា ភាពខ្វះចន្លោះនៃកិច្ចសន្យា ដែលមានលក្ខណៈ ស្តង់ដាដែលធ្វើឡើងជាមួយនិយោជកនៅក្នុងប្រទេសដែលទទួលយកពលករ គឺនៅតែមានបញ្ហាហើយក៏មានករណីមួយចំនួន ដែលកិច្ចសន្យាការងារត្រូវបានចុះហត្ថលេខានៅក្នុងប្រទេសដែលបញ្ជូនពលករ ត្រូវបានជំនួសដោយកិច្ចសន្យាថ្មីនៅក្នុងប្រទេសដែលបានទទួលយកពលករវិញ។[5]

**៤. ភាពខ្វះខាតនៃការបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដា មុនពេលចេញដំណើរ៖** ការបណ្តុះបណ្តាល មុនពេលចេញដំណើរ គឺមានសារៈសំខាន់ណាស់ដើម្បីរៀបចំអោយពលករចំណាកស្រុកអាចរៀនសម្របខ្លួនទៅនឹងវប្បធម៌ និងរៀបចំឲ្យពួកគេអាចធ្វើការងារនៅក្នុងបណ្តាប្រទេសដែលទទួលយកពលករ។ នៅក្នុងប្រទេសកម្ពុជា ការបណ្តុះបណ្តាលមុនចេញដំណើរមានដូចជា៖ ការបណ្តុះបណ្តាលទៅលើវប្បធម៌ ភាសា ការទំនាក់ទំនង បញ្ហាសុខភាព និងចំណេះដឹងផ្នែកច្បាប់ ត្រូវបានផ្តល់តាមរយៈអង្គការក្រៅរដ្ឋាភិបាលមួយចំនួន និងភ្នាក់ងារជ្រើសរើសពលករចំណាកស្រុក។ ទោះបីជាការបណ្តុះបណ្តាលមុនចេញដំណើរគឺជាការតព្វកិច្ច (មាត្រា៧ នៃអនុក្រឹត្យ១៩០) ប៉ុន្តែមិនមានស្តង់ដាណាមួយ ដែលកំណត់ពីបែបផែននៃការបណ្តុះបណ្តាល ឬកម្មវិធីសិក្សាមុនការចេញដំណើរដែលបានរៀបចំជាស្រេចឡើយ។[6]

---

[3]Policy on Labour Migration for Cambodia, 2010.
[4] Max Tunon and Khleang Rim, Cross-border labour migration in Cambodia: Considerations for the national employment policy, ILO Asia-Pacific Working Paper Series, October 2013. p. 2.
[5]Chan Sophal (December 2009), Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study, CDRI's Working Paper Series No. 44. P. 56.
[6]Ibid,p. 57.

## III. គោលនយោបាយ និងក្របខ័ណ្ឌច្បាប់

**១.** យន្តការច្បាប់ និងស្ថាប័នទទួលខុសត្រូវ ត្រូវមានជាចាំបាច់ដើម្បីផ្តល់ព័ត៌មានដល់ពលករចំណាកស្រុកអំពីការធ្វើការនៅក្រៅប្រទេស និងសិទ្ធិរបស់ពួកគេនៅកន្លែងការងារ ដើម្បីឲ្យការធ្វើចំណាកស្រុកទៅក្រៅប្រទេសនោះ ប្រកបដោយសុវត្ថិភាព ហើយពលករចំណាកស្រុកត្រូវបានការពារ។ កម្ពុជាបានផ្តួចផ្តើម និងបន្តការធ្វើ អនុវត្តគោលនយោបាយ ព្រមទាំងបង្កើតស្ថាប័នដើម្បីពង្រឹងអភិបាលកិច្ចនៃដំណើរការនៃការធ្វើចំណាកស្រុក។[7]

**២. អនុក្រឹត្យលេខ៥២៖** ភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលបន្ទុកលើការងារពលករចំណាកស្រុកគឺនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃអគ្គនាយកដ្ឋានការងារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ អនុក្រឹត្យលេខ ៥២ ក្នុងឆ្នាំ២០០៥ នេះចែងថាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវមានកាតព្វកិច្ចចំនួន២ ទាក់ទងនឹងការងារចំណាកស្រុក៖ (១) ធ្វើឲ្យប្រសើរឡើងនូវបទប្បញ្ញត្តិទាក់ទងនឹងការគ្រប់គ្រងនូវសេវាផ្តល់ការងារនៅក្រៅប្រទេស តាមរយៈក្រុមហ៊ុនឯកជន និងការជំរុញការងាររបស់ពលករកម្ពុជានៅក្រៅប្រទេស (២) សម្របសម្រួល និងសហការជាមួយក្រសួងពាក់ព័ន្ធ អង្គភាព និងអង្គការជាតិ អន្តរជាតិនានា។[8]

**៣. អនុក្រឹត្យលេខ ១៩០៖** រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត អនុក្រឹត្យលេខ ១៩០ នៅខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងនូវការបញ្ជូនពលករកម្ពុជាទៅបរទេសតាមរយៈភ្នាក់ងារជ្រើសរើសឯកជន ជំនួសឲ្យអនុក្រឹត្យលេខ៥៧ នៅឆ្នាំ១៩៩៥។ អនុក្រឹត្យនេះទទួលស្គាល់នូវផលប៉ះពាល់ជាវិជ្ជមាននៃការធ្វើចំណាកស្រុក ទៅលើការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍធនធានមនុស្ស។ អនុក្រឹត្យក៏ពង្រឹងនូវក្របខ័ណ្ឌគតិយុត្តិ សម្រាប់ធ្វើការគ្រប់គ្រងការងារចំណាកស្រុក និងការការពារពលករចំណាកស្រុក។[9]

**៤. ប្រកាស៖** ដើម្បីអនុវត្តអនុក្រឹត្យលេខ ១៩០ ខាងលើនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាសចំនួន ០៣ ទៀត រួមមាន៖

- ប្រកាសលេខ០៤៥ ឆ្នាំ២០១៣ ស្តីពីនិយមន័យនៃវាក្យស័ព្ទដែលមាននៅក្នុងអនុក្រឹត្យលេខ១៩០
- ប្រកាសលេខ០៤៦ ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការជ្រើសរើស និងការតម្រង់ទិសមុនការចេញដំណើរ
- ប្រកាសលេខ ០៤៧ ឆ្នាំ២០១៣ ស្តីពីភ្នាក់ងារជ្រើសរើសពលករ

**៥. សន្ធិសញ្ញាអន្តរជាតិ៖** កម្ពុជាក៏ជាភាគីហត្ថលេខីទៅនឹងអនុសញ្ញាអន្តរជាតិ ដូចខាងក្រោមរួមមាន៖

---

[7] Max and Khleang, P. ix.
[8] Ibid. P. 7.
[9] Ibid. P. 10.

- អនុសញ្ញាអន្តរជាតិស្ដីពីការការពារសិទ្ធិរបស់ពលករចំណាកស្រុកនិងសមាជិកគ្រួសារឆ្នាំ១៩៩០[10]
- អនុសញ្ញាលេខ ៩៧ ឆ្នាំ១៩៤៩ ស្ដីពីការធ្វើចំណាកស្រុកដើម្បីការងារ
- អនុសញ្ញាលេខ ១៤៣ ឆ្នាំ១៩៧៥ ស្ដីពីពលករចំណាកស្រុក
- អនុសញ្ញាលេខ ១៨១ ឆ្នាំ១៩៩៧ ស្ដីពីភ្នាក់ងារឯកជនក្នុងការផ្ដល់ការងារ
- អនុសញ្ញាលេខ ១៨៩ ឆ្នាំ២០១១ ស្ដីពីពលករការងារតាមផ្ទះ[11]

**៦. កិច្ចព្រមព្រៀងទ្វេភាគី និងក្នុងតំបន់៖** កម្ពុជាបានចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍អាស៊ានស្ដីពីការការពារ និងលើកកម្ពស់នូវសិទ្ធិរបស់ពលករចំណាកស្រុកដែលបានអនុម័តកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៧ និងអនុម័តសេចក្ដីថ្លែងការណ៍ទីក្រុងបាងកក ស្ដីពីការធ្វើចំណាកស្រុកមិនស្របច្បាប់នៅឆ្នាំ១៩៩៩។[12] ជាងនេះទៀត កម្ពុជាក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសថៃ កូរ៉េ គុយវ៉ែត កាតា និងប្រទេសជប៉ុន ដើម្បីគ្រប់គ្រងរាល់ការបញ្ជូនពលករកម្ពុជាទៅកាន់ប្រទេសទាំងនោះ។

## IV. ការអនុវត្តល្អនៅក្នុងប្រទេសកម្ពុជា

**១.** ដោយបានឆ្លងកាត់ដំណាក់កាលជាច្រើននៃការធ្វើចំណាកស្រុក កម្ពុជាបានរៀនសូត្របានយ៉ាងច្រើនពាក់ព័ន្ធទៅនឹងការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារ និងបានអនុវត្តនូវវិធានការណ៍ល្អៗក្នុងការដោះស្រាយបញ្ហាដែលកើតឡើងពីការធ្វើចំណាកស្រុកដើម្បីរកការងារ។ វិធានការណ៍ទាំងនោះអាចត្រូវបានចាត់ទុកជាវិធានការណ៍ល្អៗដែលអាចយកទៅអនុវត្តបន្តនៅតំបន់ផ្សេងៗទៀតក្នុងតំបន់។ វិធានការណ៍ទាំងនោះរួមមាន៖

**២. គោលនយោបាយនៃការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារ៖** ដោយមានការគាំទ្រពីអង្គការពលកម្មអន្តរជាតិ (ILO) កម្ពុជាបានរៀបចំបង្កើតនូវគោលនយោបាយអំពីការធ្វើចំណាកស្រុកដើម្បីការងារដោយមានការចូលរួមពីអ្នកពាក់ព័ន្ធដើម្បីដោះស្រាយនូវរាល់បញ្ហា និងបញ្ហាប្រឈមដែលកើតមានឡើងពីការធ្វើចំណាកស្រុកដើម្បីរកការងារ។ គោលនយោបាយនេះផ្ដោតលើផ្នែកសំខាន់ៗចំនួន៣ គឺ៖ ១)អភិបាលកិច្ចនៃការធ្វើចំណាកស្រុកដើម្បីការងារ ២)ការការពារ និងការផ្ដល់សិទ្ធិអំណាចដល់ពលករធ្វើចំណាកស្រុក និង ៣) ទាញយកប្រយោជន៍ ពីការធ្វើចំណាកស្រុកដើម្បីការងារសម្រាប់ការអភិវឌ្ឍន៍។ ការរំពឹងទុកពីការរៀបចំគោលនយោបាយនេះ គឺនឹងមានអភិបាលកិច្ចល្អលើការធ្វើចំណាកស្រុកដើម្បីការងារ ភ្នាក់ងារជ្រើសរើសពលករនឹងត្រូវបានរឹតបន្តឹង ការផ្ដល់

---

[10]http://treaties.un.org/Pages/ViewDetails.aspx?mtdsg_no=IV-13&chapter=4&lang=en
[11]For the status of Cambodia regarding these Conventions please see http://www.ilo.org/dyn/normlex/en/f?p=1000:11210:0::NO:11210:P11210_COUNTRY_ID:103055
[12]HingVutha, LunPide, and PhannDalis (August 2011), Irregular Migration from Cambodia – Characteristic, Challenges and Regulatory Approach, CDRI's Working Paper Series No. 58.P. 23.

ការគាំទ្រដល់ពលករចំណាកស្រុក ការបង្កើននូវប្រាក់បញ្ញើពីបរទេសជាអតិបរមា និងការផ្តល់ការគាំទ្រក្នុងការធ្វើសមាហរណកម្មពលករចំណាកស្រុកដែលបានត្រលប់មកវិញ។

**៣. ការផ្តល់វគ្គបណ្តុះបណ្តាលមុនចាកចេញដំណើរ៖** យោងតាមប្រកាសលេខ១០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកាលពីឆ្នាំ២០០៦ ស្តីអំពីការអប់រំអំពីមេរោគហ៊ីវ និងជម្ងឺអេដស៍ (HIV/AIDS) ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងសិទ្ធិការងារសម្រាប់ពលករចំណាកស្រុកកម្ពុជា ដែលទៅធ្វើការនៅក្រៅប្រទេសបានតម្រូវឲ្យមានវគ្គបណ្តុះបណ្តាល មុនចាកចេញដំណើរសម្រាប់ពលករចំណាកស្រុក ដែលធ្វើឲ្យពួកគេអាចការពារខ្លួនរបស់ពួកគេពីជំងឺផ្សេងៗជាពិសេសពីមេរោគហ៊ីវ និងជម្ងឺអេដស៍(HIV/AIDS)។ ជាមួយគ្នាផងដែរ យោងទៅតាមមាត្រា២០ នៃអនុក្រឹត្យលេខ១៩០ កាលពីឆ្នាំ២០១១ តម្រូវឲ្យភ្នាក់ងារស្វែងរកការងារឲ្យពលករ ផ្តល់នូវមធ្យោបាយនានាដល់ពលករចំណាកស្រុក ក្នុងការទំនាក់ទំនងស្ថានទូតកម្ពុជានៅក្នុងប្រទេស ដែលពលករចំណាកស្រុកត្រូវបានបញ្ជូនទៅ។ សៀវភៅណែនាំអំពីការតម្រង់ទិសមុនការចាកចេញដំណើរត្រូវបានរៀបចំឡើងកាលពីឆ្នាំ២០១០ ដោយមានការគាំទ្រពីអង្គការទេសន្តប្រវេសន៍អន្តរជាតិ(IoM) ដោយផ្តោតលើដំណាក់កាលដែលត្រូវធ្វើមុន និងក្រោយការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស។[13]

**៤. ការរៀបចំអនុស្សរណៈយោគយល់គ្នា៖** អនុសារណៈយោគយល់គ្នារវាងប្រទេសដែលមានពល-ករចំណាកស្រុក និងប្រទេសទទួលពលករចំណាកស្រុក គឺជាយុទ្ធសាស្ត្រល្អមួយក្នុងកិច្ចការពារពលករចំណាកស្រុក។ ទិន្នន័យបានបង្ហាញថា ចំនួនពលករចំណាកស្រុកស្របច្បាប់មានការកើនឡើងប្រមាណ ១៧៣% ចន្លោះពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ចាប់តាំងពីការមានការចុះអនុសារ-ណៈយោគយល់គ្នារវាងកម្ពុជា និងថៃ។[14] ខ្លឹមសារនៃអនុសារណៈយោគយល់គ្នានេះផ្តោតលើនីតិ-វិធីក្នុងការធ្វើចំណាកស្រុក ទប់ស្កាត់ការធ្វើចំណាកស្រុកនិងការធ្វើការងារខុសច្បាប់ និងការជួញដូរមនុស្ស ដំណើរការប្រកបដោយប្រសិទ្ធភាពសម្រាប់ការធ្វើមាតុភូមិនិវត្តរបស់ពលករចំណាកស្រុក និងកិច្ចការពារពលករចំណាកស្រុកពីរាល់ទម្រង់នៃការរំលោភបំពាន។[15]

**៥. សេនានុព័ន្ធការងារ (labour attaché)៖** កម្ពុជាបានតែងតាំងសេនានុព័ន្ធការងារនៅតាមស្ថានទូតកម្ពុជាក្នុងប្រទេសទទួលពលករចំណាកស្រុក ដើម្បីតាមដាន និងទទួលខុសត្រូវលើបញ្ហាការចំណាកស្រុក ដើម្បីពិនិត្យវាយតម្លៃលើការងារ និងនិយោជក មុននឹងអនុញ្ញាតឲ្យពលករទៅធ្វើការនៅក្នុងប្រទេសទទួលពលករចំណាកស្រុក និងផ្តល់កិច្ចសហការជាមួយប្រទេសទទួលពលករចំណាកស្រុកក្នុងកិច្ចការពារពលករចំណាកស្រុក។

---

[13]International Organization for Migration, “Safe Migration: A Pre-Departure Orientation Manual for Migrant Workers.” Cambodia, 2010.
[14]Max and Khleang, p. 2.
[15]http://ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_160944.pdf

**៦. ការកាត់បន្ថយការចំណាយ៖** នៅមុនឆ្នាំ ២០០៩ ពលករចំណាកស្រុកកម្ពុជាត្រូវចំណាយច្រើនជាង១៣០ ដុល្លាសហរដ្ឋអាមេរិក សម្រាប់ថ្លៃលិខិតឆ្លងដែន នឹងរង់ចាំក្នុងរយៈពេលយូរជាងមួយខែមុនពេលទទួលបានលិខិតឆ្លងដែននេះ។ បន្ទាប់ពីឆ្នាំ២០០៩ តម្លៃនៃការធ្វើលិខិតឆ្លងដែនត្រូវបានបញ្ចុះមកត្រឹម ២០ ដុល្លាសហរដ្ឋអាមេរិក និងមិនគិតថ្លៃតែម្តង ចាប់ពីចុងឆ្នាំ២០១៤។[16] កិច្ចការនេះធ្វើឡើងក្នុងគោលបំណង ដើម្បីលើកទឹកចិត្តដល់កម្មករចំណាកស្រុកមិនឲ្យធ្វើការចំណាកស្រុកដោយខុសច្បាប់។

**៧. យន្តការការពារត្រូវបានដាក់ចេញតាមរយៈការបង្កើតស្ថាប័នទទួលខុសត្រូវ៖** ក្រុមការងារសម្រាប់ការធ្វើចំណាកស្រុក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករចំណាកស្រុក។ ក្រុមការងារនេះត្រូវបានបង្កើតឡើងក្រោមលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនិងការជួញដូរមនុស្ស។

**៨. ដៃគូរសង្គម៖** ការចូលរួមពីដៃគូរសង្គម គឺជាវិធីសាស្ត្រមួយផ្សេងទៀតក្នុងការការពារពលករចំណាកស្រុក។ គណៈកម្មាធិការសហជីពពាណិជ្ជកម្មកម្ពុជាសម្រាប់ការធ្វើចំណាកស្រុក (CTUC-M) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១២ ជាសម្លេងរួមមួយនៃសហព័ន្ធចំនួន៣ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករចំណាកស្រុកស្របតាមគោលការណ៍នានា របស់អង្គការពលកម្មអន្តរជាតិ (ILO)។ ការចូលរួមពីអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិត្រូវបានជំរុញនៅក្នុងប្រទេសកម្ពុជា។ មានការកើនឡើងនូវការចូលរួមពីអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិក្នុងកិច្ចសហការ និងដំណើរការ នៃការពិគ្រោះយោបល់លើការធ្វើគោលនយោបាយពាក់ព័ន្ធនឹងបញ្ហាការធ្វើចំណាកស្រុក ដើម្បីគាំទ្រដល់ពលករចំណាកស្រុក ដោយធានានូវការធ្វើគោលនយោបាយនឹងដោះស្រាយបញ្ហា ដែលកើតឡើងពីការធ្វើចំណាកស្រុកបានគ្រប់ជ្រុងជ្រោយ។[17]

## V. សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ

១. ប្រទេសកម្ពុជាបានធ្វើដំណើរឆ្ងាយ ហើយបានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការការពារ និងការផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តប្រវេសន៍។ រដ្ឋាភិបាលបានទទួលស្គាល់ និងជំរុញការងារចំណាកស្រុកជាឧបករណ៍ក្នុងការកាត់បន្ថយភាពក្រីក្រ។ ប្រទេសកម្ពុជាបានចុះសច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន ដើម្បីជួយសម្រួលដល់ការធ្វើចំណាកស្រុកដោយរលូននៃកម្មកររបស់ខ្លួន។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងថ្នាក់តំបន់ និងទ្វេភាគីក៏ត្រូវបានចុះហត្ថលេខាផងដែរ។ ការអនុវត្តល្អជាច្រើន រាប់ចាប់ពីការកាត់បន្ថយការចំណាយរហូតដល់ការបង្កើតសេនានុពន្ធ័

[16] https://bnglegal.com/sys-content/uploads/2015/03/150112-MLU-January-pdf.pdf
[17] Max and Khleang, p. 8.

ការងារត្រូវបានអនុវត្ត។ នៅតែមានរបាយការណ៍ស្តីពីពលករទេសន្តរប្រវេសន៍កម្ពុជាទទួលការរំលោភបំពាន និងធ្វើបាបនៅក្រៅប្រទេស។ ដើម្បីជួយសម្រួលដល់ពលករទេសន្តរប្រវេសន៍ឲ្យប្រសើរជាងមុន ជម្រើសគោលនយោបាយមួយចំនួនដែលគួរតែត្រូវបានពិចារណា៖

**២ .ធ្វើការដាក់កំហិតការបណ្តុះបណ្តាលមុនការចេញដំណើរជាចាំបាច់៖** ការបណ្តុះបណ្តាលស្តីពីបញ្ហាវប្បធម៌ ភាសារ ការទំនាក់ទំនង សុខភាព និងចំណេះដឹងពីច្បាប់ ភាគច្រើនផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករ។ ទោះបីជា ការបណ្តុះបណ្តាលមុនពេលធ្វើដំណើរជាកំហិត (មាត្រា៧ នៃអនុក្រឹត្យលេខ១៩) ពលករចំណាកស្រុកមួយចំនួនមិនបានទទួលការបណ្តុះបណ្តាលមុនពេលចាកចេញអ្វីទាំងអស់ ដែលធ្វើពួកគេងាយរងគ្រោះនឹងការរំលោភបំពាន និងការធ្វើកេងប្រវ័ញ្ច។ ទីភ្នាក់ងារជ្រើសរើសពលករ គួរតែត្រូវបានផាកពិន័យពីការបញ្ជូនពលករទៅធ្វើការនៅបរទេសដោយមិនបានទទួលការបណ្តុះបណ្តាលមុនពេលចាកចេញ។ ទីភ្នាក់ងារជ្រើសរើសពលករគួតែត្រូវបានត្រួតពិនិត្យឲ្យមានប្រសិទ្ធិភាពចំពោះបញ្ហានេះ។

**៣ .ការធានាបាននូវការទទួលខុសត្រូវរួម៖** នៅក្នុងករណីពលករចំណាកស្រុកត្រូវបានរំលោភបំពាន ការទទួលខុសត្រូវ ត្រូវតែបែងចែករវាងនិយោជក ទីភ្នាក់ងារជ្រើសរើសពលករ និងទីភ្នាក់ពាក់ពន្ធ័ផ្សេងទៀត។ មានរបាយការណ៍ថាទីភ្នាក់ងារជ្រើសរើសបុគ្គលិកគេចវេសពីការទទួលខុសត្រូវរបស់ខ្លួននៅពេលដែលសិទ្ធិរបស់កម្មករត្រូវបានរំលោភបំពាន ស្ទើតែគ្រប់ករណីទាំងអស់ ត្រូវបានផ្ទេរទៅអង្គការក្រៅរដ្ឋាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទៅវិញ។

**៤ .បង្កើតមូលដ្ឋានទិន្នន័យស្តីពីពលករទេសន្តរប្រវេសន៍៖** ស្ថិតិស្តីពីពលករទេសន្តរប្រវេសន៍គឺជាឧបករណ៍មួយសម្រាប់វាស់វែងពីផលប៉ះពាលពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ហើយអាចឲ្យរដ្ឋាភិបាលថ្លឹងថ្លែង ពីអត្ថប្រយោជន៍ជាមួយនឹងបញ្ហាប្រឈមសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការប្រមូល ការវិភាគ និងការចែករំលែកព័ត៌មានទាក់ទងនឹងបញ្ហាពលករទេសន្តរប្រវេសន៍ទាំងពីប្រទេសដែលបញ្ជូនចេញ និងប្រទេសដែលទទួលពលករ គឺជាផ្នែកមួយក្នុងការលើកកម្ពស់ការការពារពលករទេសន្តប្រវេសន៍។[18] ប៉ុន្តែជាការលំបាកណាស់ ក្នុងការទទួលបានទិន្នន័យពេញលេញ និងថ្មីៗទាក់ទងនឹងការធ្វើចំណាកស្រុកនៅប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ ការបង្កើតនូវមូលដ្ឋានទិន្នន័យរបស់ពលករទេសន្តរប្រវេសន៍ឲ្យបានទូលំទូលាយ គួរតែជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀតនៅប្រទេសកម្ពុជា ក៏ដូចជាសម្រាប់ប្រទេសដទៃទៀត។ ព័ត៌មានទាក់ទងនឹងការធ្វើចំណាកស្រុក គួរត្រូវបានចែករំលែកបន្ថែមទៀតយ៉ាងទូលំទូលាយ ការយល់ដឹងគួរតែលើតំកើងនៅក្នុងចំណោមសាធារណៈជនទូទៅ។

[18] The 6th ASEAN Forum on migration labour, 26-27 November 2013, Bandar Seri Begawan, Brunei Darussalam. Retrieved from http://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/meetingdocument/wcms_234228.pdf

**៥ .បន្តវិធានការកាត់បន្ថយចំណាយ៖** ហេតុផលមួយដែលបង្ខំឲ្យពលករទេសន្តប្រវេសន៍ជ្រើសរើសពិធីសាស្ត្រខុសច្បាប់ក្នុងការចំណាកស្រុកគឺប្រាក់តម្រៃខ្ពស់ និងការចំណាយពេលរងចាំយូ។ ការកាត់បន្ថយចំណាយ និងពេលវេលារងចាំនឹងជួយកាត់បន្ថយចំនួនពលករចំណាកស្រុកខុសច្បាប់។

**៦. ពង្រឹងសម្ថភាពរបស់សេនានុពន្ធ័ការងារ៖** កម្ពុជាបានតែងតាំងសេនានុពន្ធ័ការងារនៅស្ថានទូតកម្ពុជានៅប្រទេសដែលទទួលពលករទេសន្តប្រវេសន៍ ដើម្បីទទួលខុសត្រូវលើបញ្ហារបស់ពលករទេសន្តប្រវេសន៍ រួមទាំងពិនិត្យលើការងារ និងនិយោជកមុនពេលអនុម័តឲ្យពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសគោលដៅ។ ទោះយ៉ាងណាក៏ដោយ ហាក់ដូចជាមានការខ្វះខាតនូវការសម្របសម្រួលគ្រប់គ្រាន់រវាងសេនានុព័ន្ធការងារ និងក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសពលករ។ ការសម្របសម្រួលរវាងភាគីពាក់ព័ន្ធសំខាន់ៗ គួរត្រូវបានពង្រឹង ព្រមទាំងសមត្ថភាពរបស់សេនានុពន្ធ័ការងារផងដែរ។ មុខងារនៃសេនានុពន្ធ័ការងារ និងមន្ត្រីទូត គួរតែត្រូវធ្វើឲ្យបានប្រសើរឡើង។ ពួកគេគួរតែត្រូវបានបណ្តុះបណ្តាលយ៉ាងល្អ និងគាំទ្រគ្រប់គ្រាន់ដើម្បីផ្តល់ការការពារឲ្យមានប្រសិទ្ធិភាពនៅកន្លែងការងាររបស់ពលករ ។

# ឯកសារយោង


1. Chan Sophal (December 2009), Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study, CDRI’s Working Paper Series No. 44.
2. Hing Vutha, LunPide, and Phann Dalis(August 2011), Irregular Migration from Cambodia – Characteristic, Challenges and Regulatory Approach, CDRI’s Working Paper Series No. 58.P. 23.
3. International Organization for Migration, “Safe Migration: A Pre-Departure Orientation Manual for Migrant Workers.” Cambodia, 2010.
4. International Organization for Migration, “Safe Migration: A Pre-Departure Orientation Manual for Migrant Workers.” Cambodia, 2010.
5. Max Tunon and Khleang Rim, Cross-border labour migration in Cambodia: Considerations for the national employment policy, ILO Asia-Pacific Working Paper Series, October 2013.
6. Policy on Labour Migration for Cambodia, 2010.
7. For the status of Cambodia regarding these Conventions please see http://www.ilo.org/dyn/normlex/en/f?p=1000:11210:0::NO:11210:P11210_COUNTRY_ID:103055
8. http://ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/publication/wcms_160944.pdf
9. http://treaties.un.org/Pages/ViewDetails.aspx?mtdsg_no=IV-13&chapter=4&lang=en
10. http://www.iom.int/key-migration-terms (accessed 01/08/2015)
11. https://bnglegal.com/sys-content/uploads/2015/03/150112-MLU-January-pdf.pdf